Decalssified to Public
06 September 2012



# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## អង្គបុរេជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ០២/១៤-០៨-២០០៦-អវតក/អបជ　　　　កាំង ហ្គេកអ៊ាវ ហៅ ឌុច

**ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧**

**ម៉ោង ០១: ០៥ នាទី**

**សវនាការដោយសម្ងាត់**

**ចៅក្រមជំនុំជម្រះ៖**

លោក ប្រាក់ គឹមសាន　　　　ប្រធានអង្គបុរេ

លោក រ៉ូវ៉ាន់ ដោននីង

លោកស្រី ខាទីនខា ឡាហ៊ូស

លោក ហួត វុទ្ធី

លោក ប៉ែន ពេជ្រសាលី

**ក្រឡាបញ្ជី៖**

លោក ដួន សុរាសី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក រ៉ូប៊ឺត ពើទីត

អាឡិចសាន់ឌឺ បើត

ដឺហ្គិន អាស្មាន

**មេធាវីការពារជនត្រូវចោទឈ្មោះ កាំង ហ្គេកអ៊ាវ**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ

*(ផ្នែកនេះ គឺជាការដកស្រង់ចេញពីវាយចម្លងនៃដំណើរការនីតិវិធីជាសាធារណៈនៅទំព័រទី៣៥)*

*(អង្គចៅក្រមចូលមកដល់សាលសវនាការ)*

**ប្រធានអង្គបុរេ៖**

សូមបន្តសវនាការតទៅទៀត សូមអញ្ជើញ ចៅក្រម រ៉ូវ៉ាន់ដោននីង ។

**ចៅក្រម រ៉ូវ៉ាន់ ដោននីង៖**

សំណួរនេះទាំងលោកមេធាវីនិងលោកព្រះរាជអាជ្ញា។ យើងមើលវិធានទី២១ គោលការណ៍ជាមូលដ្ឋាន ជាពិសេស ២១.១(ឃ) ដែលបានចែងថានៅគ្រប់ដំណាក់កាលនៃនិតិវិធីដែលប៉ះពាល់ទៅដល់ជនជាប់ចោទនឹងត្រូវការជូនដំណឹងអំពីទៅដល់សិទ្ធិរបស់ជននោះអំពីការនៅស្ងៀមមិនឆ្លើយតប។

ខ្ញុំសូមស្តាប់មតិអំពីមេធាវីការពារ ឌុច ហើយនឹងសហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទស្សនៈរបស់ខ្លួនផ្ទាល់ទាក់ទងទៅនឹងអំពីការខកខានជាជាក់ស្តែងរបស់ជនជាប់ចោទ ដែលថានឹងបានប្រាប់ពីសិទ្ធិនេះ "អំពីសិទ្ធិរបស់គាត់ក្នុងការនៅស្ងៀមមិននិយាយ"។ នៅគ្រប់ដំណាក់កាលនៃដំណើរការរឿងក្តីដោយកត់សម្គាល់ថា តាមការដែលយើងខ្ញុំបានអានទៅលើអំពីកំណត់ហេតុនៃការបង្ហាញខ្លួនជាដំបូងនឹងការសម្ភាសន៍ ហើយយើងយល់ថាគាត់បានទទួលដំណឹងអំពីសិទ្ធិរបស់គាត់តែម្តងនៅថ្ងៃទី២១ ខែកក្កដា។ តើនេះជាបញ្ហាដែលត្រូវតែលើកយកមកនិយាយឬជាអង្គហេតុដែលថាតំណាងគាត់មានមេធាវីជាអ្នកតំណាងដើម្បីស្តែងថា ជាការបោះបង់សិទ្ធិក្នុងការទទួលការជូនដំណឹងថាគាត់មានសិទ្ធិនៅស្ងៀមមិននិយាយនោះ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

បាទ! អរគុណ។ ចំពោះសំណួរនេះរបស់លោកចៅក្រម បាទ! ទាក់ទងនឹងមេធាវីការពារយើងសូម យោងទៅលើគោលការណ៍នៃប្រព័ន្ធ*"ស៊ីវិលឡូ"* ហើយចាប់តាំងពីពេលដែល ឬចាប់ផ្តើមនៃការស៊ើបអង្កេតចៅក្រមបានផ្តល់នូវការណែនាំនេះ គឺវាមានលក្ខណៈគ្រប់គ្រាន់ហើយ។ វាមិនចាំបាច់នៅក្នុងប្រព័ន្ធ *"ស៊ីវិលឡូ"* រំឭកពីសិទ្ធិនេះទេនៅក្នុងពេលនៃការសួរចម្លើយម្តងៗគឺមិនថាក្នុងប្រព័ន្ធច្បាប់កម្ពុជា ឬប្រព័ន្ធច្បាប់បារាំងទេ។

គឺនៅក្នុងចាប់ផ្តើមនៃការនៃការចាំផ្តើមនៃការស៊ើបអង្កេត ហើយនៅក្នុងកន្លងពេលនៃការស៊ើបអង្កេតទាំងអស់។ ផ្ទុយទៅវិញ វាជាការចាំបាច់គឺយើងអាចធ្វើនៅក្នុងដំណាក់កាលនៃអង្គបុរេជំនុំជម្រះដូចដែលយើងបានធ្វើពីម្សិលមិញហើយវាក៏ជាការចាំបាច់ដែលថានឹងអាចធ្វើជាថ្មីម្តងទៀតនៅពេលជន

ដែលត្រូវចោទបង្ហាញខ្លួនជាថ្មីនៅមុខចៅក្រមថ្មី គឺមានន័យថានៅអង្គជំនុំជម្រះថ្នាក់ដំបូង។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថាបន្ទាប់ពី សហចៅក្រមស៊ើបអង្កេតបានណែនាំ ការណែនាំនេះបានធ្វើឡើងសម្រាប់រយៈពេលនៃការស៊ើបអង្កេតទាំងមូលតែម្តង។

**ចៅក្រម រ៉ូវ៉ាន់ ដោនទីង៖**

ដូច្នេះយើងត្រូវពិនិត្យមើលវិធានដែលចែងថានៅគ្រប់ដំណាក់កាលនិតិវិធីនោះ។

**លោក ហ្វ្រង់ស្វ័រ រូ:**

បាទ! ដំណាក់កាលទី១ នោះនៃនិតិវិធីគឺការស៊ើបអង្កេត បាទដូច្នេះនៅពេលចាប់ផ្តើមដំណាក់កាលនៃការស៊ើបអង្កេតគឺត្រូវណែនាំអំពីវិធាននេះ។

បាទ! ដំណាក់កាលទី២ នៃនិតិវិធីគឺបណ្តឹងឧទ្ធរណ៍នៃដីការសហចៅក្រមស៊ើបអង្កេត ។ ដំណាក់កាលទី៣នៃនីតិវិធីគឺ ការបង្ហាញខ្លួននៅចំពោះមុខចៅក្រមតុលាការថ្នាក់ទី១។ ដូច្នេះហើយ ខ្ញុំសង្កេតឃើញថាដំណាក់កាលនៃនិតិវិធី គឺជាអ្វីដែលយើងបានអនុវត្តនៅមុខតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា។ ដំណាក់កាលមុនការជំនុំជម្រះក្តី ហើយពេលជម្រះក្តី ហើយនៅពេលធ្វើបណ្តឹងឧទ្ធរណ៍គឺយើងនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ហើយវិធាននេះគឺបានរំឭកនៅពេលដំណាក់កាលដំបូងនៃការស៊ើបអង្កេត។ បាទ! អញ្ចឹងយើងមិនមានការផ្លាស់ប្តូរនៃដំណាក់កាលនៃនីតិវិធីទេ។

**ចៅក្រម ឡាហ្វ៊ីស៖**

ចម្លើយនេះមានន័យថាលោកបានបោះបង់សិទ្ធិរបស់ខ្លួនក្នុងការទទួលដំណឹង នៅពេលតុលាការសម្រេចនៅចុងក្រោយប្រហែលថាគ្រប់ដំណាក់កាលនៃរឿងក្តី នឹងអាចមានន័យផ្សេង?

**លោក ហ្វ្រង់ស្វ័រ រូ:**

ទេ! បើខ្ញុំប្រកាន់ថានៅក្នុងដំណាក់កាលនីមួយៗនៃនីតិវិធីគឺវិធាននេះត្រូវតែគោរព ប៉ុន្តែដំណាក់កាលទី១ គឺជាដំណាក់កាលស៊ើបអង្កេតនៅពេលនេះ។ នៅពេលដែលយើងផ្លាស់ប្តូរនៅដំណាក់កាលនៃនីតិវិធីយើងត្រូវតែរំឭកឡើងវិញនូវសិទ្ធិនេះ ដូចដែលយើងបានធ្វើកាលព្រឹកពីម្សិលមិញបាទ នៅពេលណាដែលធ្វើដូច្នេះគឺថាខ្ញុំមិននិយាយថា បើខ្ញុំមិនធ្វើទេ ខ្ញុំនឹងជម្រាបជូន។

**ចៅក្រម រ៉ូវ៉ាន់ ដោនទីង៖**

ប្រសិនបើយើងមានស្ថានភាពមួយដែលថាជនត្រូវចោទមិនមានអ្នកតំណាងទេនោះហើយយើងមានការសម្ភាសន៍ចំពោះទម្លើករណ៍ ឬក៏ការអះអាងថាគឺថ្ងៃទី២១ កក្កដា ហើយការជូនដំណឹង គឺបាន

ជូនដំណឹងអំពីសិទ្ធិថ្ងៃនោះពេលនោះគេបានធ្វើការសម្ភាសន៍នៅ១ខែក្រោយ ហើយមិនបានជូនដំណឹងទេ ព្រោះនៅក្នុងដំណាក់កាលដដែល។ ហើយបន្ទាប់មកការសម្ភាសន៍នោះគឺថាពីរអាទិត្យក្រោយពីនោះមក ហើយក៏មិនបានផ្តល់ការជូនដំណឹងមិនបានផ្តល់ព័ត៌មានទេ។ ថាតើយើងស្ថិតនៅក្នុងស្ថានភាពមួយដែល គេអាចនិយាយថាសិទ្ធិជាមូលដ្ឋានរបស់បុគ្គលក្នុងការស្ងៀមមិនឆ្លើយ ត្រូវបានផ្តល់គ្រប់គ្រាន់ជូនទៅជន ជាប់ចោទទេ? គេអាចនឹងភ្លេចអ្វីដែលកើតមាន២ខែទៅហើយនោះ។ ការព្រួយបារម្ភរបស់យើងនោះ តើសិទ្ធិជាមូលដ្ឋាននេះ ដែលជាសិទ្ធិមូលដ្ឋានវាអាចត្រូវតែរំឭកត្រូវតែជម្រាបញឹកញាប់ដើម្បីកុំឱ្យភ្លេច។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ចំណែកខ្ញុំៗគិតថា បើចាប់តាំងពីពេលដែលអត្ថបទច្បាប់បាននិយាយថានៅក្នុងគ្រប់ដំណាក់-កាលគឺមានន័យថា ក្នុងន័យដំណាក់កាលនីមួយៗខុសៗគ្នា ប៉ុន្តែប្រសិនបើជាអង្គជំនុំជម្រះថាចៅក្រម ត្រូវតែរំឭកគ្រប់រឿង គ្រប់ពេលទាំងអស់គឺខ្ញុំមិននិយាយផ្ទុយពីនេះទេ។ ប៉ុន្តែបើខ្ញុំយោងទៅលើអត្ថបទ ច្បាប់ បើយើងនិយាយអំពីដំណាក់កាលនៃនិតិវិធី គឺជាដំណាក់កាលនៃការចាប់ផ្តើមនៃការស៊ើបអង្កេត គឺខ្ញុំសូមរំឭកថាចៅក្រមស៊ើបអង្កេតមិនអាចៗមិនអាចៗ អាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមាន នៃមេធាវីទេ គឺនៅពេលដែលនិតិវិធីនៃការជំនុំជម្រះចាប់ផ្តើម គឺមានន័យថាជាការចាប់ផ្តើមនៃការស៊ើប អង្កេត គឺត្រូវមានវត្តមាននៃមេធាវី ហើយបន្ទាប់មកទៀតក៏គឺចៅក្រមមិនអាចសួរចម្លើយជនត្រូវចោទ ដោយគ្មានវត្តមាននៃមេធាវីនោះទេ។

**លោក រ៉ូបឺត ពើទីត៖**

ខ្ញុំសូមបញ្ជាក់ថា ហើយក៏ស្ថិតនៅក្នុងដំណើរការរៀនសូត្រដែរចំពោះខ្ញុំ កាលណាចូលទៅដល់ នីតិវិធីដែលអនុវត្តចំពោះតុលាការនេះ ក៏ប៉ុន្តែខ្ញុំយល់ថាអ្វីដែលជាការណែនាំ មាត្រា២១(ឃ) មានន័យ ថា ដំណាក់កាលនៃដំណើរការរឿងក្តីនេះដូចដែលសហសេវិកខ្ញុំបានលើកឡើងនោះ។ ខ្ញុំមិនបានដឹង អំពីការអនុវត្តនៅក្នុងប្រព័ន្ធ *ស៊ីវិលឡូ* ជាយុត្តាធិការផ្សេងទៀតនោះទេ ខ្ញុំដឹងច្បាស់ថាការអនុវត្តនៅ ក្នុងប្រព័ន្ធច្បាប់ *ខំមិនឡូ* ប៉ុន្តែខ្ញុំជាថ្មីម្តងទៀតខ្ញុំដឹងច្បាស់អំពីការអនុវត្តនៅក្នុងបរិបទអន្តរជាតិ។ បាទ! គឺពាក្យថាប្រុងប្រយ័ត្ននេះ បាទគឺគ្រប់គ្រាន់ហើយបើជាក់ស្តែងជនដែលត្រូវចោទពុំមានមេធាវីតំណាង ទេ នៅពេលដែលទទួលឱ្យស្ថិតនៅក្រោមការពិនិត្យរបស់តុលាការ ហើយព្រះរាជអាជ្ញាក៏ត្រូវវត្តមាន នៅមុខយើង។ យើងក៏ត្រូវតែផ្តល់ដំណឹងដោយប្រុងប្រយ័ត្នបំផុតដែលអាចធ្វើទៅបានទាក់ទងទៅនឹង ការប្រុងប្រយ័ត្ននេះដើម្បីឱ្យប្រាកដថា គឺថាការលើកលែងសិទ្ធិមួយណាមួយដើម្បីមានមេធាវីការពារ

ឬសិទ្ធិមួយដើម្បីនៅស្ងៀមមិននិយាយ គឺថាសិទ្ធិទាំងអស់នេះគឺជាសិទ្ធិជាក់លាក់របស់ជននោះ គឺថាត្រូវមានអ្នកការពារឬមិនមាន ដូច្នេះចំណុចនេះក៏អនុវត្តនូវគ្រប់យុត្តាធិការទាំងអស់ដែលត្រូវទទួលស្គាល់ដែលថា ដំណើរការតុលាការត្រូវតែឆ្លើយតបនូវរាល់សេចក្ដីសម្រេចដែលធ្វើឡើង គឺត្រូវតែធ្វើឡើងដោយមានព័ត៌មានគ្រប់គ្រាន់បើមានសិទ្ធិរបស់បុគ្គលដែលថាគេចោទពីបទឧក្រិដ្ឋដ៏ធ្ងន់នោះគឺថាគេអាចការពារបានក្នុងអត្ថប្រយោជន៍ដ៏ល្អបំផុតរបស់គេនោះ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

បាទ! ខ្ញុំសូមឱ្យមើល១វិធាន៥៨នៃបទបញ្ជាផ្ទៃក្នុងនៅចំណុចទី២។ បាទ! នៅក្នុងនោះគឺមានដែលនិយាយថា ជនត្រូវចោទ ការសួរសំណួរជនត្រូវចោទត្រូវមានវត្តមានមេធាវី លើកលែងតែជនត្រូវចោទឆ្លើយថា មិនចាំបាច់មានវត្តមានរបស់ខ្លួននិងត្រូវសរសេរនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ ដោយឡែកដោយមានអត្តលេខា។ បាទ! ចំណុចទី៣នៃវិធានទី៣គឺ នៃវិធាននេះគឺធ្វើឱ្យខ្ញុំមានការភ្ញាក់ផ្អើលថា ពីព្រោះបានបង្ហាញថានៅក្នុងករណីបន្ទាន់ ដោយមានការយល់ព្រមពីជនត្រូវចោទសហចៅក្រមស៊ើបអង្កេតអាចចោទដោយមិនចាំបាច់មានវត្តមានរបស់គាត់(មេធាវីរបស់គាត់)។

បាទ! ខ្ញុំមានការសោកស្ដាយថាចំណុចត្រូវបានបញ្ចូល បាទ! ខ្ញុំគិតថាគួរតែមានកិច្ចប្រជុំពេញអង្គត្រូវតែកែប្រែចំណុចទី២ និងទី៣ ហើយត្រូវបញ្ជាក់ឡើងវិញ ហើយត្រូវបញ្ជាក់ថាបើសិនជាមេធាវីមិនអាចនៅទីនេះ គឺមិនអាចមានវត្តមានគឺសហព្រះរាជអាជ្ញាត្រូវតែអាននៅមាត្រា២១(ឃ)គឺជាការកែទម្រង់សំខាន់មួយ។

**លោកស្រី ជា លាង៖**

ខ្ញុំសូមចូលរួមហើយសូមឆ្លើយនូវអ្វីដែលលោកចៅក្រម ដោននីង បានលើកនូវសំណួរនេះឡើងទីមួយពាក់ព័ន្ធនូវអ្វីដែលថាត្រូវតែជូនដំណឹងគ្រប់ដំណាក់កាលទាំងអស់។ ខ្ញុំយល់ថា ចំណុចនេះវាមានការពាក់ព័ន្ធនុវមាត្រា៥៧នៃបទបញ្ជាផ្ទៃក្នុងក៏ដូចជាមាត្រា១៤៣ នៅក្នុងនិតិវិធីព្រហ្មទណ្ឌទើបតែអនុម័តកន្លងមកនេះ។ ករណីចាំបាច់បំផុតដំណាក់កាលខុសគ្នាពីមួយទៅមួយនេះបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត ឬចៅក្រមស៊ើបអង្កេតគាត់ប្រាប់គាត់ជូនដំណឹងទៅជនត្រូវចោទនោះនៅពេលដែលគាត់ចូលខ្លួនជាលើកដំបូង។ អញ្ចឹងខ្ញុំក៏យល់ឃើញថាមានលក្ខណៈដូចដែលថាលោកមេធាវីខាងអន្តរជាតិដែលលើកឡើងថា បញ្ហានេះវាជាការមួយស្ថិតក្នុងដំណាក់កាលស៊ើបអង្កេត អញ្ចឹងតួនាទីរបស់ចៅក្រមស៊ើបអង្កេតដែលគាត់បញ្ជាក់បង្ហាញនៅពេលនេះគឺគាត់បានប្រាប់និងជូនដំណឹងទៅជនត្រូវចោទនូវសិទ្ធិរបស់

គាត់។ ខ្ញុំជឿថា ខ្ញុំក៏មិនជំទាស់ដែរ បើសិនចៅក្រមនឹងមានគំនិតថានឹងអាចសុំស្នើដាក់ឱ្យជាក់លាក់នឹងដាក់ការជូនដំណឹងគ្រប់ពេលទាំងអស់ ដល់ជនត្រូវចោទមុននឹងត្រូវសួរទៅលើជនត្រូវចោទនោះ។

ទីពីរ ពាក់ព័ន្ធនឹងបញ្ហាមេធាវីដែលហ្វ្រង់ស្វ័រ រូ មិញបានលើកឡើងផងដែលនោះ បញ្ហាដែលពាក់ព័ន្ធនឹងមាត្រា៥៨ដែលក្នុងបទបញ្ជាផ្ទៃក្នុងនេះដែរ។ យើងក៏មាននៅក្នុងមាត្រា១៤៥ នៃនិតិវិធីព្រហ្មទណ្ឌដែរ គឺនីតិវិធីព្រហ្មទណ្ឌដែលទើបតែអនុម័តនៅពេលកន្លងថ្មីៗនេះដែរ គឺមានលក្ខណៈចែងដូចគ្នាបេះបិតនៅក្នុង៣ដំណាក់កាល។

ការសួរចម្លើយត្រូវមានវត្តមានមេធាវីនេះជាចំណុចមួយ។ ២) អាចសួរយកចម្លើយបានក្នុងករណីអវត្តមាន នៅពេលដែលអវត្តមានមេធាវី តែករណីនេះប្រើប្រាស់នៅពេលជនត្រូវចោទអនុញ្ញាតប៉ុណ្ណោះ។ ៣) ករណីបន្ទាន់ៗឧទាហរណ៍ថាជនត្រូវចោទនោះគាត់មានបញ្ហាណាមួយដែលយើងជៀសមិនបាន ហើយយើងចាំបាច់យើងត្រូវការចម្លើយរបស់ជនត្រូវចោទគឺយើងអាចធ្វើបាន។ នេះគឺជានីតិវិធីដែលយើងអនុវត្តនៅប្រព័ន្ធ *ស៊ីវិលឡ* ហើយជានិតិវិធីដែលអនុវត្តនៅកម្ពុជា។ អញ្ចឹង ខ្ញុំគ្រាន់តែលើកជាយោបល់ប៉ុណ្ណឹង ហើយសូមឱ្យអង្គបុរេពិចារណានៅចំណុចទាំងពីរនេះ ព្រោះយើងយល់ថាវិធានផ្ទៃក្នុងដែលចែងសម្រាប់អង្គជំនុំជម្រះនេះ ភាគច្រើនគឺបានយកអ្វីដែលជានីតិវិធីក្រមនីតិវិធីដែលយើងអនុវត្តកន្លងមក។

**ចៅក្រម ឡាហ្វីស៖**

ខ្ញុំមានសំណួរមួយទៀត ប៉ុន្តែខ្ញុំសូមបញ្ជាក់ពីដំបូងដែលពីលោក រូ ពីព្រោះដែលលោកលើកឡើងថានៅអង្គបុរេជំនុំជម្រះ ត្រូវរំឭកអំពីសិទ្ធិនៅស្ងៀម គឺជាសារសំខាន់ តើថាវាមានន័យថានៅពេលដែលអង្គបុរេជំនុំជម្រះដោះស្រាយទៅលើបណ្តឹងឧទ្ធរណ៍ខុសគ្នាៗនៅក្នុងគោលគំនិតរបស់លោកតើធ្វើយ៉ាងម៉េចពីជនត្រូវចោទដូចគ្នា?

**លោក ហ្វ្រង់ស្វ័រ រូ៖**

បាទ! យើងអាចចោទសំណួរនេះ បើយើងមិនស្ថិតក្នុងវិស័យដូចគ្នានឹងសហចៅក្រមស៊ើបអង្កេតទេ។ គឺការស៊ើបអង្កេតគឺជាដំណាក់កាលដំបូងនៃនិតិវិធីគឺវាច្បាស់លាស់ណាស់ ប៉ុន្តែអង្គបុរេជំនុំជម្រះ នឹងពិនិត្យទៅលើបណ្តឹងឧទ្ធរណ៍ទៅលើចំណុចដាច់ខាតខុសគ្នា ហើយជាការពិតគឺយើងអាចធ្វើអន្តរាគមន៍នៅពេលដែលជាការចាំបាច់នៅក្នុងការធ្វើបណ្តឹងឧទ្ធរណ៍នីមួយៗ ពេលនោះ អង្គបុរេជំនុំជម្រះត្រូវតែពន្យល់ប្រាប់ពីសិទ្ធិនេះ។ ប៉ុន្តែ បើសិនជាយើងនិយាយអំពីដីការធ្វើបណ្តឹងឧទ្ធរណ៍សម្រាប់

ថ្ងៃនេះ ឬក៏យើងអាចធ្វើនៅពេលសប្តាហ៍ក្រោយនៅពេលសវនាការមួយទៀត។ អញ្ចឹង! វាមិនចាំបាច់ទេព្រោះវាធ្វើរួចហើយក្នុងការប្រាប់នូវសិទ្ធិនេះ។

**ចៅក្រម ឡាហ្វ៊ួស៖**

អញ្ចឹង! ឥឡូវនេះមានសំណួរមួយទៀត តុលាការបានអាននៅក្នុងកំណត់ហេតុដែលទាក់ទងនឹងការបង្ហាញខ្លួនដំបូង តើលោក រូ មានវត្តមាននៅពេលនោះដែរឬទេ? ហើយគាត់មិនមានវត្តមានក្នុងការសួរតទល់គ្នាៗ វាហាក់ដូចជាជនត្រូវចោទបានបង្ហាញថាគាត់ចង់បានជំនួយពីមេធាវីអន្តរជាតិ។ ហើយតុលាការបានអានថាចំណុចមួយដែលខាងអយ្យការបានលើកឡើងថា ដំណើរការនីតិវិធីសម្រាប់ការចុះឈ្មោះនៅក្នុងបញ្ជីគណៈមេធាវីមិនទាន់បានកំណត់នៅឡើយ។ មិនទាន់បានបញ្ចប់នៅឡើយ។

អង្គបុរេបានមើលទៅលើសំណុំរឿងហើយ មិនមានកំណត់ហេតុតាមវិធានទី៥៨.២ ដែលជនត្រូវចោទបោះបង់សិទ្ធិទទួលមេធាវីរបស់គាត់ ជាពិសេសមេធាវីអន្តរជាតិ។ ហើយគឺបាននិយាយយោងថាគឺ សិទ្ធិមានមេធាវីនេះគឺជាសិទ្ធិមូលដ្ឋាន ជាសិទ្ធិសារវន្តបានពណ៌នាហើយបានចែងក្នុងនៅក្នុងវិធានទី២១។ ដូចដែលសហការីខ្ញុំបានលើកឡើងហើយថា ខ្ញុំៗចង់ឮមតិយោបល់ពីខាងមេធាវី។

**ចៅក្រម រ៉ូវ៉ាន់ ដោននីង៖**

ខ្ញុំចង់បន្ថែមទៅលើសំណួរនឹងមុនបន្ទាប់មេធាវីៗឆ្លើយតប ផ្នែកនៃការឆ្លើយតបនោះគឺថាខ្ញុំចង់បានការពិចារណាទៅលើថាតើមេធាវីមានន័យយ៉ាងម៉េចពីព្រោះតែយើងមើលទៅលើវិធានទី២១ ហើយនិងវិធានទី៥៧គឺវាចែងអំពីមេធាវី។ ប្រសិនបើយើងមើលវិធានទី២២ យើងអាចសន្និដ្ឋានអំពីការបង្ហាញអំពីមេធាវីមានន័យថាមេធាវីជាតិ ហើយនិងមេធាវីអន្តរជាតិ។ ២២.១(ក) និង២២.១(ខ)គឺមានសិទ្ធិជ្រើសរើសពីមេធាវីជាតិនិងមេធាវីអន្តរជាតិ។ អញ្ចឹងវាអាស្រ័យទៅលើយើងឲ្យនិយមន័យដែលយើងអនុវត្តទៅលើមេធាវី។

**លោក រ៉ូប៊ីត ពើទីត៖**

ខ្ញុំចង់ប្រហែលជា ចង់ចង្អុលទៅលើភាសាបារាំងនៃវិធានទី២២.១(ក) បានចែងថាមេធាវីជាតិ ឬក៏មេធាវីបរទេស មិនមែនភាសា“និង”ទេ គឺភាសា “ឬ”។ ២២.១(ក) និយាយជាភាសាបារាំង។ អញ្ចឹងយើងគិតអំពីសិទ្ធិដែលមាន ។

**ចៅក្រម រ៉ូវ៉ាន់ ដោននីង៖**

នៅក្នុងភាសាបារាំងថាមានមេធាវីជាតិ ឬមេធាវីអន្តរជាតិមិនមែនទាំងពីរទេ អញ្ចឹងវាហាក់

មានលក្ខណៈចម្លែកនៅក្នុងករណីហ្នឹង បើយើងយកភាសាបារាំងក្នុងការអនុវត្តតើត្រឹមត្រូវដែរឬទេ? អញ្ចឹងពាក្យថា "ឬ"នេះមានន័យថាជាមួយ រួមជាមួយ។

**លោក រ៉ូបឺត ពើទីត៖**

តើខ្ញុំសូមបញ្ជាក់នៅក្នុងភាសាខ្មែរវិញមានន័យយ៉ាងណា?

**លោកស្រី ជា លាង៖**

ខ្ញុំបានអានដែរ គឺភាសាខ្មែរប្រើពាក្យ "និង" ទេ គឺមិនបានប្រើពាក្យ"អ្វី" "ឬ"ដូចគាត់ថា នោះទេ។ ពីព្រោះថាពាក្យ"ឬ"នេះ គឺករណីមួយណាក៏បានដែរ។ ប៉ុន្តែពាក្យ"និង" នេះចាំបាច់គឺត្រូវតែទាំងពីរវាខុសគ្នា អញ្ចឹងខ្ញុំមិនដឹងទេ ប្រហែលជាអាចស្នើខាងគណៈកម្មការបទបញ្ជាផ្ទៃក្នុងឬមួយយ៉ាងម៉េចខ្ញុំមិនដឹងទេ សូមឱ្យអង្គបុរេពិចារណាចុះអំពីបញ្ហាភាសានេះ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ប្រសិនជាខ្ញុំ ខ្ញុំអាចជូននូវការពន្យល់បន្ថែមគឺក្នុងរបៀបដែលយើងត្រូវអនុវត្ត យើងនឹងត្រូវតែអនុវត្តតាមរបៀបជារូបិយជាក់ស្តែង គឺមិនត្រូវធ្វើរបៀបជាអរូបិយនៅថ្ងៃទី៣១ ខែកក្កដា ខ្ញុំមានវត្តមានក្នុងការពិភាក្សាដេញដោល ប៉ុន្តែគឺខ្ញុំមិនមានសិទ្ធិផ្លូវការក្នុងការនិយាយពីព្រោះអីខ្ញុំមិនទាន់បានយល់ព្រមពីគណៈមេធាវី ហើយខ្ញុំមិនទាន់បានស្បថ។ ដូច្នេះខ្ញុំធ្វើជាអ្នកពិគ្រោះបល់នៃសហការីរបស់ខ្ញុំគឺ លោក ការ សាវុត្ថ យើងគិតថាជាលក្ខណៈជាក់ស្តែងសិទ្ធិរបស់ជនត្រូវចោទគឺត្រូវបានគោរព គោរពតាំងពីចាប់តាំងពីពេលដែលយើងបានធ្វើការជាមួយគ្នាជាមួយ លោក ការ សាវុត្ថ គឺនៅក្នុងការពិភាក្សាដេញដោល ហើយដែលគាត់បាននិយាយក្នុងនាមមេធាវីការពារ។

បន្ទាប់ពីពេលដែលខ្ញុំត្រូវបានទទួលស្គាល់ពីគណៈមេធាវីកម្ពុជា ហើយខ្ញុំបានស្បថ ខ្ញុំអាចចូលក្នុងអន្តរាគមន៍ជាផ្លូវការជាមួយសហចៅក្រមស៊ើបអង្កេត នេះជាអ្វីដែលកើតឡើងជាបន្តបន្ទាប់។

**លោក រ៉ូបឺត ពើទីត៖**

ប្រសិនបើជាលោកចៅក្រមអាចឱ្យខ្ញុំនោះថាសេចក្តីដែលបានលើកឡើងនោះនឹងវាពាក់ព័ន្ធទៅនឹងលោក រូ ដែលលើកឡើងដោយខ្ញុំនៅក្នុងការជំនុំជម្រះ។ នៅក្នុងសវនាការគឺយើងត្រូវតែមានគឺមានវត្តមាននៃសមភាពរវាងអយ្យការនិងមេធាវី។ ហើយលោកមេធាវី នៅក្នុងនោះដែលមិនទាន់បានស្បថអញ្ចឹងហើយគាត់មិនមានសិទ្ធិនៅក្នុងការចូលសវនាការ ដូច្នេះវាៗទាក់ទងនឹងសិទ្ធិនៅពេលសវនាការ។

ប៉ុន្តែ ខ្ញុំចង់ចង្អុលបង្ហាញក្នុងការបញ្ជាក់ថាតាមជំហររបស់ខ្ញុំ ប្រហែលជាជំហររបស់យើងគឺ

សិទ្ធិរបស់ជនត្រូវចោទគឺត្រូវមានមេធាវីតាមជម្រើសរបស់គាត់នៅក្នុងគម្រោងការដែលចែង ដែលបានផ្តល់ឲ្យគាត់។ អញ្ចឹងមេធាវីជាតិ ឬក៏ទាំងពីរ អញ្ចឹងគឺថាគាត់ត្រូវមានសិទ្ធិ អញ្ចឹងគាត់ត្រូវអនុវត្តសិទ្ធិនៅក្នុងការចង្អុលបង្ហាញដែលយើងបានបញ្ជាក់។

**ចៅក្រម ឡាហ្វ៊ីស៖**

អញ្ចឹងក្នុងការកត់ត្រា លោក រូ មានវត្តមាននៅពេលដែលសួរតទល់ ពីព្រោះតែខ្ញុំមិនឃើញនៅក្នុងកំណត់ហេតុ អញ្ចឹងគាត់មានវត្តមាន។ អញ្ចឹងខ្ញុំដកចេញពីចំណុចហ្នឹង។

**ប្រធានអង្គបុរេ៖**

បាទ! សវនាការ សូមសម្រាក១៥នាទី ហើយជនត្រូវចោទត្រូវរក្សានៅកន្លែងដែលមិនចេញទៅទេ ហើយចូលមកវិញយើងនឹងប្រកាសជាសាធារណៈវិញ សវនាការជាសាធារណៈវិញបន្ទាប់ពីចូលមក។

**លោក រ៉ូប៊ឺត ពើទីត៖**

សួរទៅលើការវិភាគនេះយ៉ាងម៉េចដែរ?

**ចៅក្រម រ៉ូវ៉ាន់ ដោននីង៖**

ប្រហែលមុនពេលចូលមកវិញថាតើមានបញ្ហាផ្សេងទៀតទេដែលលោកមេធាវីចង់លើកឡើងក្នុងសម្ងាត់ហ្នឹងដែលគាត់ចង់លើក អញ្ចឹងចំណុចទាំងនឹងដែលលោកចង់លើកក្នុងសវនាការសម្ងាត់ដែលលោកចង់លើកហ្នឹង តើមានចំណុចផ្សេងទៀតដែលឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ប្រហែលជាមេធាវីការពារចង់លើក សូមបញ្ជាក់ថា យើងបានផ្តល់ជូនទៅក្រឡាបញ្ជីនៅអាសយដ្ឋានរបស់ជនត្រូវចោទដែលនឹងរស់នៅ ប្រសិនបើជាអង្គបុរេសម្រេចឲ្យគាត់នៅមានសេរីភាព ហើយអាសយដ្ឋាននេះ គឺត្រូវតែរក្សាជាការសម្ងាត់។

**ប្រធានអង្គបុរេ៖**

សូមប្រកាសសម្រាក១៥នាទី។

*(សវនាការដោយសម្ងាត់ [ពីទំព័រទី ៣៥ ដល់ទំព័រទី ៤២] ផ្អាកនៅម៉ោង ១:៤៥ នាទី)*